**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តាងនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ៣០១
ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៥
សាលដីកា
លេខៈ ២០៦/៤៧
ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០០៦ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............ ជាចៅក្រមរបាយការណ៍
៣-លោក ............ ជាចៅក្រម
៤-លោក ................. ជាចៅក្រម
៥-លោក ................. ជាចៅក្រម

ក្រឡាបញ្ជី
-កញ្ញា .....................

តំណាងមហាអយ្យការ
-លោក ................. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៣៣(ឈ)ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៨៧ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ មប (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤ឆ្នាំ ជាតិខ្មែរមុខរបរកងរាជអាវុហ្គខេត្តក្រចេះ ទីលំនៅៗភូមិវត្ត ឃុំត្រចេះ ស្រុកក្រចេះ ខេត្តក្រចេះ ។

-ចុងចម្លើយឈ្មោះ សហ(ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរមុខរបរធ្វើសិប្បកម្មឈើ ទីលំនៅៗភូមិឫស្សីចារ ឃុំថ្មក្រៃ ស្រុកត្រចេះ ខេត្តក្រចេះ ។

មានមេធាវីលោក............ .

**កម្មវត្ថុបណ្តឹង**: ប្តឹងទារប្រាក់ .

បានឃើញបណ្តឹងសាទុក្ខលេខ១២៥ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៥ របស់លោក............ មេធាវីការពារឱ្យឈ្មោះសេងហួ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៣៣(ឈ)ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសាលដីកាទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៣០១ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី៣០-០៩-២០០៣ របស់ដើមចោទឈ្មោះមប បានប្តឹងទារប្រាក់ពីឈ្មោះសេងហួ ដោយមូលហេតុឈ្មោះសេង ហួ បានខ្ចីចងការប្រាក់ខ្លួន តែដល់ថ្ងៃកំណត់កិច្ចសន្យា ឈ្មោះនេះពុំសងខ្លួនវិញឡើយ ។

បានឃើញសាលក្រមថ្លៃម្សវេណីលេខ២៩-ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ២០០៨ របស់តុលាខេត្តក្រចេះ ដែលមាន ខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី៣០-៩-២០០៣ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី២០-០១-២០០៤ របស់ឈ្មោះឆយ គឹមឆាយ (ប្តី) ឈ្មោះសេង គឹមយឹ, (ប្រពន្ធ) ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ នឹងគតិច្បាប់ ។

៣-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី២១-០១-២០០៤ របស់ឈ្មោះសេង ប៊ុនទី (ប្តី) ឈ្មោះហៅ ស៊ីណាល់ (ប្រពន្ធ) ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

៤-បង្គាប់ឱ្យឈ្មោះសេង ហូវ(ប្តី) ឈ្មោះគឹម លូន (ប្រពន្ធ) សងប្រាក់ជំពាក់ ទៅឈ្មោះមប ប្តី ឈ្មោះសិន ណោង (ប្រពន្ធ) ជាប្រាក់ ៣៩០០០ដុល្លា (បីម៉ឺនប្រាំបួនពាន់ដុល្លាអាមេរិក) និងអត្រាការប្រាក់៥%ក្នុងមួយឆ្នាំ ចាប់ពីថ្ងៃចុះកិច្ចសន្យា រហូតសងគ្រប់ចំនួន និងឱ្យសងការខាតបង់ពេលវេលាជាប្រាក់ ៤០០០ដុល្លា(បួនពាន់ដុល្លាអាមេរិក) សុំលើសពីនេះត្រូវបដិសេធចោល ក្នុងករណីគ្មានប្រាក់ សុំឱ្យរឹបអូសទ្រព្យសម្បត្តិធានាសំណាង បន្ទាប់ពីការប្តឹងឱ្យរឹបអូសទ្រព្យរបស់អ្នកប្តឹងទី១ ក្នុងករណីរឹងរូសពុំព្រមសងត្រូវចាប់ដាក់គុកទាំងពីរនាក់ប្តីប្រពន្ធដើម្បី ទាប្រាក់ សំណង ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីពីពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តីជាប្រាក់ ១៨០០៛ រង្វាន់ ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០៛ សរុប ៨០០០៛ ។ ប្រាក់នេះ បានកាត់យកពីប្រាក់៧០០០៛ ដែលដើមចោទបាន បង់រួចហើយ កាលបើហួសឧទ្ធរណ៍ត្រូវបង្គាប់ឱ្យចុងចម្លើយបង់សងទៅដើមចោទវិញ និងបង្គាប់ឱ្យបង់ពន្ធសមាមាត្រ ១% ស្មើ $\frac{43000\$ X 1}{100} = 4300\$$ ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ៨០%ស្មើ $\frac{1720000R X 80}{100} = 1376000R$ និងបង់ហិប្រាក់ ក្រឡាបញ្ជីទូទាំងប្រទេស២០%ស្មើ $\frac{1720000R X 20}{100} = 344000R$ ប្រាក់នេះត្រូវដើមចោទបង់ទុកជាមុនហើយឲ្យចុង ចម្លើយបង់សងទៅដើមចោទវិញ នាពេលអនុវត្តសាលក្រម ។

៦-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី២២-៣-២០០៤ ចំពោះមុខដើមចោទ និងកចុងងចម្លើយចំពោះមុខដើម បណ្តឹងទាស់ឈ្មោះឆយ គឹមឆាយ សេង គឹមយី ឈ្មោះសេង ប៊ុនទី . ហៅ ស៊ីណាល់ និងប្រកាសនៅល្ងាចថ្ងៃទី២៦-៣-២០០៤ ចំពោះមុខដើមចោទឈ្មោះមប ប្តី ឈ្មោះសិន ណោង(ប្រពន្ធ) កំបាំងមុខចុងចម្លើយឈ្មោះសហ ដើមបណ្តឹង ទាស់ឈ្មោះ ឆយ គឹមឆាយ សេង គឹមយី សេង ប៊ុនទី ហោរាស៊ីណាល់ តែចាត់ទុកជាចំពោះមុខ សម្រេច
បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៩ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៥ របស់ឈ្មោះ ឆយ គឹមឆាយ ជាតតិយជន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៩ ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ២០០៤ របស់តុលាការខេត្តក្រចេះ ត្រង់ចំណុចនៃសេចក្តីសម្រេចសាលក្រមទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១០ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះ សហ ប្តឹងមិនសុខចិត្តនឹង សាលក្រមរដ្ឋប្បវេណីលេខ២៩ ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ២០០៤របស់តុលាការខេត្តក្រចេះ ត្រង់ចំណុចនៃសេចក្តី សម្រេចសាលក្រមទាំងមូល ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១១ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះ មប ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ២៩ ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ២០០៨របស់តុលាការខេត្តក្រចេះ ត្រង់ចំណុចទី៤ នៃសេចក្តីសម្រេចសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៤ របស់ឈ្មោះ សេង ប៊ុនទី ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ២៩ ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ២០០៤ របស់តុលាកាខេត្តក្រចេះ ត្រង់ចំណុចទី៣ នៃសេចក្តីសម្រេចសាលក្រម ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៣៤(ឈ) ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥-០៥-២០០៥ របស់ឈ្មោះសហ និង ឆយ គឹមឆាយ និងពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦-០៥-២០០៤ របស់ឈ្មោះសេង ប៊ុនទី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៦-០៥-២០០៥របស់ឈ្មោះមប ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ២៩ ចុះថ្ងៃទី២២-០៣-២០០៥ របស់តុលាការខេត្តក្រចេះ ទុកជាបានការដដែល ដោយគ្រាន់តែកែប្រែចំនួនប្រាក់ដើមដែលចុងចម្លើយ ត្រូវសងទៅឱ្យដើមចោទក្នុងចំណុចទី៤ នៃសេចក្តីសម្រេចពី ៣៩.០០០ដុល្លាអាមេរិក មកជាចំនួន ៤.១០០០ដុល្លាអាមេរិកវិញ និងសម្រេចលុបឃ្លាថា (បន្ទាប់ពីការប្តឹងឱ្យរឹបអូសទ្រព្យរបស់អ្នកប្តឹងទី១) ក្នុងចំណុចទី៤ និងចំណុចបង់ពន្ធសមាមាត្រក្នុងចំណុចទី៥ នៃសេចក្តីសម្រេចចោលជាអសារបង់។ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល ។

៤-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍១៣០០០៛គឺពន្ធហ្នឹងនិងពន្ធចុះបញ្ជីក្តី២៥៥០៛រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥០០០៛ និងអាជ្ញាធរតុលាការ៥.០០០៛ ។ នៅពេលសាលក្រមនេះចូលជាស្ថាពរ បង្គាប់ឱ្យឈ្មោះសហ បង់ពន្ធសមាមាត្រ១%លើចំនួនប្រាក់ដើម ការប្រាក់ និងថ្ងៃខាតបង់ពេលវេលា ។

៥-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៧-០៨-២០០៤ ចំពោះមុខដើមចោទកំបាំងមុខចុងចំម្លើយ និងតតីយជន និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦-០៨-២០០៨ ចំពោះមុខ ដើមចោទ កំបាំងមុខចុងចម្លើយ និងតតិយជន បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ១២៧ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះសេងហួរ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ១៣៤(ឈ)ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចសាលដីកាទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៣(ឈ)ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី០៧-១២-២០០៤ របស់ឈ្មោះសហ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់និងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីកំបាំងមុខលេខ១៣៤(ឈ) ចុះថ្ងៃទី២៦-០៨-២០០៨ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៤-០២-២០០៥ ចំពោះមុខដើមចោទ និងមេធាវីតំណាងចុងចម្លើយ កំបាំងមុខតតិយជន និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៥-១២-២០០៥ ចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ និងតតិយជន តែទុកជាចំពោះមុខបើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ១២៥ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៥ របស់លោក ........... មេធាវីការពារឱ្យឈ្មោះសេងហួរ ប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ៣៣ (ឈ)ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ត្រង់ចំណុច នៃសាលដីកាទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៦ របស់ឈ្មោះសហ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ៣៣(ឈ) ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និង សម្រេច ។

បានស្តាប់ចម្លើយរបស់ឈ្មោះសហ នាពេលសវនាការថានៅថ្ងៃទី១៧-០៧-២០០០ ខ្លួនខ្ចីប្រាក់ចំនួន ២៨.៥០០ដុល្លាប្រាកដមែន ខ្លួនបង់ការប្រាក់៤%ជារៀងរាល់ខែ ។ នៅឆ្នាំ២០០១ ខ្លួនខាតព្រោះរដ្ឋាភិបាលបិទលើពេលនោះលោកមប បង្ខំឱ្យខ្លួនផ្តិតមេដៃទាំងប្តីទាំងប្រពន្ធ ហើយថា ឈប់យកការប្រាក់ហើយ ។ ខ្លួនទទួលស្គាល់បំណុលដែលជំពាក់នៅសល់តែ១១.៣០០ដុល្លា ហើយបើលោកមប សុខចិត្តយកដី ខ្លួនប្រគល់ឱ្យដីទំហំ៥០ម x ៥០ម ខ្លួនមិនទទួល ស្គាល់កិច្ចសន្យាជំពាក់ប្រាក់ ៤១.០០០ដុល្លាទេ ។

បានស្តាប់ចម្លើយរបស់ឈ្មោះមប នាពេលសវនាការថា នៅថ្ងៃទី២២-០៧-២០០១ ចុងចម្លើយបានខ្ចីប្រាក់ចំនួន ៤១.០០០ដុល្លា ដោយបានដាក់ឡានកាម៉ាស់៤គ្រឿង និងដាក់ដីរោងម៉ាស៊ីនអារឈើទាំងអស់ ។ ខ្លួនមិនទទួលស្គាល់ការដែលចុងចម្លើយថា នៅជំពាក់ខ្លួនតែ១១.៣០០ ដុល្លានោះទេ។ ខ្លួនសុំទាមទារ ៤១.០០០ដុល្លា និងសុំតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ........... ជាមេធាវីការពារឱ្យចុងចម្លើយបានលើកឡើងថា : កូនក្តីខ្លួនបានទទួលស្គាល់ហើយថា ខ្លួនបានជំពាក់ប្រាក់តែ ២៨.៥០០ដុល្លាប៉ុណ្ណោះ ក្នុងការខ្ចីនេះ គឺបានព្រមព្រៀងគ្នានូវការប្រាក់ ៤%ក្នុងមួយខែ ហើយបានឱ្យការប្រាក់ជារៀងរាល់ខែ ក្រោយមកកូនក្តីខ្លួនបានបើករោងចក្រពីរ ពេលនោះរដ្ឋាភិបាលបានបិទឈើ ធ្វើឱ្យកូនក្តីខ្លួនក្ស័យធន ហើយម្ចាស់បំណុលក៏ផ្អើលមកទារបំណុល ។ លោកមប បានធ្វើកិច្ចសន្យាជាស្រេច មកឱ្យកូនក្តីខ្លួនផ្តិតមេដៃ ។ កូនក្តីខ្លួនបានសងប្រាក់ឱ្យលោកមប និងប្រពន្ធជាច្រើនលើកច្រើនសារ គឺសង

លើកទី១ចំនួន៩៧០០ដុល្លាលើកទី២ នៅថ្ងៃទី២១-០៣-២០០២ ចំនួន ៣០០០ដុល្លាលើក ទី៣ នៅថ្ងៃទី០៣-០៥-២០០៦ ចំនួន ២០០០ដុល្លាលើកទី៤ នៅថ្ងៃទី១១-០៧-២០០២ ចំនួន៣០០០ដុល្លា, សងនៅថ្ងៃទី៣១-១០-២០០២ ចំនួន១០០០ដុល្លា សងនៅថ្ងៃទី៣១-០៨-២០០២ ចំនួន ៤០០០ដុល្លាសងនៅថ្ងៃទី៣០-០៩-២០០២ ចំនួន ៤៧០០ដុល្លា សងនៅថ្ងៃទី០៦-០៣- ២០០៣ តាមរយៈគង្គា ហេង ហេង ចំនួន ២០០០ដុល្លា នៅសល់តែ ១១.៣០០ដុល្លា ទេ ។

**សំណូមពរៈ** សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចាល និងសុំបង្វិលសំណុំរឿង នេះទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះឡើងវិញ ។

ក្រោយពីបានស្តាប់បាយការណ៍របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសារបស់គួភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងចុងចំលើយ

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១២៥ ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៥ របស់លោកមេធាវីទៀវ សុផល តំណាងឱ្យលោកសហ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលា ជំរះក្តី ។

- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ចុងចម្លើយឈ្មោះសហ ប្រពន្ធ ឈ្មោះគឹម លួន ពិតជាបានខ្ចីចងការប្រាក់ពីដើមចោទឈ្មោះ មប តាមកិច្ចសន្យាជំពាក់ប្រាក់ចុះថ្ងៃទី២២-០៧-២០០១ចំនួន ៤១០០០$US ហើយពុំទាន់បានសងទៅដើមចោទពិតប្រាកដមែន។

- យល់ឃើញថា ការដែលមេធាវីចុងចម្លើយលើកឡើងនាសវនាការនេះថា សាលាឧទ្ធរណ៍មានការខុសឆ្គងដោយបានសម្រេចបន្ថែមបំណុលចំនួន២០០០ដុល្លា ដែលតុលាការថ្នាក់ក្រោមបានកាត់ចេញពីបំណុលដើម និងមិនបានចាត់របៀបឱ្យធ្វើកោសល្យវិច័យនិងចាត់របៀបធ្វើការស៊ើបអង្កេតលើសាក្សីបន្ថែមនោះគឺជាការពុំត្រឹមត្រូវទេ ពីព្រោះថា ដើមចោទបានប្តឹងឧទ្ធរណ៍ និងចុងចម្លើយពុំជូនសំអាងទាំងអស់នៅតុលាការថ្នាក់ក្រោម តាមការបង្គាប់របស់តុលាការនេះទេ ហើយទើបតែនៅសាលាឧទ្ធរណ៍ នៅពេលជំនុំជំរះតាមបណ្តឹងទាស់របស់ចុងចម្លើយ ទើបលោក មេធាវីតំណាងឱ្យចុងចម្លើយ ស្នើសុំឱ្យធ្វើការស៊ើបអង្កេតបន្ថែមដែលជាការស្នើសុំក្នុងគោលបំណង អូសបន្លាយនីតិវិធីតុលាការ ដែលតាមគោលការណ៍ ចុងចម្លើយត្រូវមានកាតព្វកិច្ចជូនសំអាងនេះ តាំងពីតុលាការថ្នាក់ក្រោមមកម្ល៉េះ ។ ហើយលើសពីនេះទៅទៀត សំអាងទាំងនេះពុំមែនជាសំអាងដែលទើបកើតមានទេ ។

- យល់ឃើញថា ចុងចម្លើយបានទទួលស្គាល់នាពេលសវនាការនេះថា ខ្លួនពិតជាបានផ្តិត មេដៃលើកិច្ចសន្យាចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០១ ពិតប្រាកដមែន ដូច្នេះចុងចម្លើយត្រូវមាន កាតព្វកិច្ចសងបំណុលទៅដើមចោទៅវិញ តាមមាត្រ ២៩ នៃក្រឹត្យច្បាប់លេខ ៣៨គ្រច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៣៣(ឈ) ចុះថ្ងៃទី១៥ ខែកុម្ភៈឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី**

១-ទទួលបណ្តឹងសាទុក្ខលេខ ១២៥ ចុះថ្ងៃទី០៧ ខែមេសាឆ្នាំ២០០៥ របស់លោក........... មេធាវីតំណាងឱ្យចុងចម្លើយ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៣៣(ឈ) ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទបានបង់ជួសនៅតុលាការកំពូលចំនួន ១៩០០០គឺៈ

-ពន្ធចុះបញ្ជីក្តី នឹងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

ហើយតម្រូវឱ្យចុងចម្លើយសងប្រាក់ចំនួន១៩.០០០៛ នេះទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយ បង់ពន្ធសមាមាត្រតាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦។